# ឯកសារគោលជំហររួមរបស់អង្គការសង្គមស៊ីវិលកម្ពុជា
# ចាត់អាទិភាពអំពីសេចក្តីត្រូវការរបស់អ្នកដែលស្ថិតក្នុងហានីភ័យខ្ពស់ចំពោះ
# អំពើហិង្សាផ្អែកលើយេនឌ័រ (GBV) នៅក្នុងកិច្ចឆ្លើយតបចំពោះស្ថានភាពជំងឺរាតត្បាតកូវីដ១៩
# ថ្ងៃទី២ ខែមេសា ឆ្នាំ២០២០

យើងខ្ញុំជាតំណាងអង្គការសង្គមស៊ីវិល គ្រប់វិស័យទាំងអស់ក្នុងប្រទេសកម្ពុជា សូមបង្ហាញសាមគ្គីភាព ការគោរព ការសាទរ និងថ្លែងអំណរគុណចំពោះសកម្មភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីការពារពលរដ្ឋពីការរីករាតត្បាតជាសកលនៃជំងឺកូវីដ១៩ តាមរយៈការដាក់ចេញនិងអនុវត្តវិធានការចាំបាច់គួរឲ្យកត់សម្គាល់ជាច្រើនតាមរយៈស្ថាប័នពាក់ព័ន្ធដោយផ្ទាល់ និងដោយប្រយោល ជាពិសេសតាមរយៈកិច្ចប្រឹងប្រែងយ៉ាងសកម្ម របស់ក្រសួងសុខាភិបាល និងបណ្តាគ្រូពេទ្យដែលស្ថិតនៅជួរមុខកំពុងធ្វើការងារទប់ស្កាត់ និងព្យាបាលជំងឺរាតត្បាតនេះ។

អង្គការសង្គមស៊ីវិលដូចមានចុះហត្ថលេខាខាងក្រោម សូមផ្តល់ការគាំទ្រចំពោះរាជរដ្ឋាភិបាលកម្ពុជា ក្នុងការឆ្លើយតបចំពោះបញ្ហាផ្នែកយេនឌ័រ ដែលនឹងត្រូវប្រឈមបន្ថែមទៀតក្នុងដំណាក់កាលកើតឡើង និងក្រោយនៃវិបត្តិនេះ។ បញ្ហាទាំងអស់នេះរួមមានដូចជាអំពើហិង្សាផ្អែកលើយេនឌ័រ (GBV) ការរើសអើងប្រឆាំងស្ត្រី និងក្មេងស្រី ព្រមទាំងភាពចម្រុះរបស់ពួកគេ ការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី និងសុវត្ថិភាព និងសន្តិសុខសហគមន៍។ ទាំងនេះគឺជាបញ្ហាដ៏ចាំបាច់ដែលយើងខ្ញុំជឿជាក់ថា រដ្ឋាភិបាលគួរពិចារណានៅក្នុងកិច្ចឆ្លើយតបរបស់ខ្លួន ដើម្បីធ្វើឱ្យផលប៉ះពាល់ដ៏មហន្តរាយរបស់មេរោគកូវីដ១៩ មានការថយចុះ។

### *មេរោគកូវីដ១៩ មានផលប៉ះពាល់ និងហានីភ័យបន្ថែមលើការរើសអើងផ្អែកលើយេនឌ័រ*

ជំងឺកូវីដ១៩ គឺជាវីរុសរាតត្បាតដោយមិនគិតពីពូជសាសន៍ សាសនា ភេទ និន្នាការភេទ ទីតាំងភូមិសាស្ត្រ ឬសញ្ជាតិឡើយ តែយ៉ាងណាក្តី ការរាតត្បាតនេះ នឹងបង្កឱ្យមានផលប៉ះពាល់ផ្សេងៗគ្នា ទៅតាមលក្ខខណ្ឌនិងស្ថានភាពដោយឡែក ជាពិសេសក៏នឹងមានផលជះលើលក្ខណៈយេនឌ័រប្លែកពីគ្នា ដែលទាមទារឱ្យមានការគ្រប់គ្រងវិបត្តិមានលក្ខណៈឆ្លើយតបផ្នែកយេនឌ័រ។ តួនាទីរបស់ស្ត្រី និងក្មេងស្រីនៅក្នុងផ្ទះ សហគមន៍ និងកម្លាំងការងារ ធ្វើឱ្យពួកគេត្រូវប្រឈមនឹងហានីភ័យកាន់តែច្រើនឡើង ក្នុងការពើបប្រទះជាមួយមេរោគ កូវីដ១៩។ កិច្ចការទាំងអស់នេះមានដូចជា ការទទួលខុសត្រូវកិច្ចការងារក្នុងផ្ទះ និងការងារថែទាំគ្មានប្រាក់ឈ្នួល ក៏ដូចជាការបំពេញមុខរបរ ក្នុងនាមជាអ្នកផ្តល់សេវាសុខាភិបាលជួរមុខ និងអ្នកផ្តល់សេវាផ្នែកសង្គម។ តួនាទីដដែលនេះ ក៏ធ្វើឱ្យស្ត្រី និងក្មេងស្រី ព្រមទាំងអ្នកមកពីក្រុមងាយរងគ្រោះ និងក្រុមជួបការលំបាកដទៃទៀត (រួមទាំងជនភាគតិចផ្នែកយេនឌ័រ និងផ្នែកផ្លូវភេទ បុគ្គលិកថែទាំសុខភាព កម្មករនិយោជិតទេសន្តប្រវេសន៍ អ្នករកស៊ីផ្លូវភេទ ជនជាតិភាគតិច ស្ត្រីគ្មានដីធ្លី ស្ត្រី និងក្មេងស្រីមានពិការភាព អ្នកធ្វើការក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងអ្នកដទៃទៀត) ត្រូវប្រឈមនឹងហានីភ័យកាន់តែច្រើនឡើងចំពោះ GBV ក្នុងអំឡុងពេលការរាតត្បាតជំងឺជាសកលនៃជំងឺនេះ។ បញ្ហាទាំងនេះគឺអាស្រ័យដោយសារតែលទ្ធភាពមានកម្រិតកំណត់ក្នុងការទទួលបាន និងគ្រប់គ្រងលើធនធាន និងការសម្រេចចិត្តលើសេចក្តីត្រូវការនៅក្នុងផ្ទះ សំណាញ់សុវត្ថិភាពសង្គម ការផ្លាស់ទី និងលទ្ធភាពទទួលបានព័ត៌មាន/សេវា។ ថ្វីបើច្បាប់សិទ្ធិមនុស្ស អនុញ្ញាតឱ្យដាក់ដែនកំណត់ ឬនិរាករណ៍សិទ្ធិមួយចំនួនសម្រាប់គោលបំណងស្របច្បាប់ ដូចជាដើម្បីការពារសុខភាពសាធារណៈក្តី ប៉ុន្តែមានព្រំដែនកំណត់យ៉ាងតឹងរ៉ឹង ទាក់ទងជាមួយពេលវេលា របៀប និងទំហំដែលអាចដាក់ដែនកំណត់លើសិទ្ធិទាំងនេះ។ ការដាក់ឱ្យសកម្មភាពចែករំលែកព័ត៌មាននៅលើប្រព័ន្ធផ្សព្វផ្សាយសង្គមជាបទឧក្រិដ្ឋ គឺពុំមែនជាចម្លើយតបនោះទេ ហើយអាចបង្កគ្រោះថ្នាក់ច្រើនជាងបង្កផលល្អ។

ដូចគ្នានេះដែរ ការបិទសំឡេងសមាជិកសង្គមស៊ីវិល មិនឱ្យនិយាយចេញមកនូវការពិតដែលមិនគួរជាទីចង់បាន គឺពុំមែនជាវិធីសាស្ត្រដ៏ត្រឹមត្រូវក្នុងការការពារសង្គមឡើយ។ ដោយហេតុនេះ រាល់ការដាក់ដែនកំណត់ទាំងឡាយ ចាំបាច់ត្រូវធ្វើឡើងក្នុងគោលបំណងស្របច្បាប់ ហើយចាំបាច់ត្រូវតែមានលក្ខណៈសមាមាត្រជាមួយគោលបំណងនោះ មានភាពចាំបាច់ (មានប្រសិទ្ធភាព និងផ្អែកលើភស្តុតាង) មានដែនកំណត់ពេលវេលា (មិនមានលក្ខណៈរើសអើង) និងអនុលោមតាមច្បាប់។ កិច្ចខិតខំក្នុងការត្រៀមខ្លួននិងឆ្លើយតបចំពោះមេរោគកូវីដ១៩ ចាំបាច់ត្រូវមានលក្ខណៈឆ្លើយតបផ្អែកយេនឌ័រ ចំពោះសេចក្តីត្រូវការពិសេសដោយឡែកទាំងអស់នេះ ហើយត្រូវផ្តល់អាទិភាពដល់ការគ្រប់គ្រងហានិភ័យផ្អែក GBV នៅក្នុងកិច្ចឆ្លើយតប។

- ស្របពេលដែលបុព្វហេតុឫសគល់នៃ GBV គឺទំនាក់ទំនងអំណាចមិនស្មើភាពគ្នា ការរាតត្បាតជាសកលនៃមេរោគកូវីដ១៩ ទំនងជាបង្កើនកត្តាញុាំងឱ្យកើតមាន GBV ដែលគេបានដឹងកន្លងមក ឱ្យមានការកើនឡើងថែមទៀត។ ការលើកឡើងបញ្ជាក់ពីអង្គការសិទ្ធិស្ត្រី និងអ្នកផ្តល់សេវា GBV ក្នុងប្រទេសចិន និងទីកន្លែងដទៃទៀតជុំវិញពិភពលោកក្នុងអំឡុងពេល ជំងឺកូវីដ១៩ កន្លងមក ក៏ដូចជាឆ្លងតាមបទពិសោធន៍នៃការរាតត្បាតជំងឺនាពេលអតីតកាល បានបង្ហាញឱ្យឃើញនូវហានីភ័យកាន់តែច្រើនឡើងនៃ GBV។[1] ក្នុងប្រទេសកម្ពុជា ស្ត្រី និងក្មេងស្រីអាចជួបប្រទះហានីភ័យកាន់តែខ្ពស់នៃអំពើហិង្សាប្រព្រឹត្តដោយដៃគូស្និទ្ធស្នាល និងអំពើហិង្សាក្នុងគ្រួសារ អាស្រ័យដោយភាពតានតឹងកាន់តែខ្ពស់នៅក្នុងគ្រួសារ បណ្តាលមកពីអសន្តិសុខស្បៀងអាហារ និងអសន្តិសុខសេដ្ឋកិច្ច ការភ័យខ្លាចចំពោះវីរុស ការបង្ខាំងឱ្យនៅក្នុងផ្ទះ និងអសមត្ថភាពក្នុងការនៅឱ្យឃ្លាតឆ្ងាយពីអ្នករំលោភបំពាន បន្ទុកកាន់តែច្រើនរបស់ស្ត្រីនៅក្នុងកិច្ចការងារថែទាំគ្មានប្រាក់ឈ្នួល និងលទ្ធភាពតិចជាងមុនក្នុងការទទួលបានសេវាឆ្លើយតប GBV ដែលអាចជួយទប់ស្កាត់កុំឱ្យមានអំពើហិង្សាបន្ថែមទៀត។ ការរឹតបន្តឹងការផ្លាស់ទី កាត់បន្ថយសមត្ថភាពរបស់ស្ត្រីក្នុងការរក្សាគម្លាតខ្លួនឯងពីប្តី ឬសមាជិកគ្រួសារដទៃទៀតដែលប្រើហិង្សា។
- ហានីភ័យកាន់តែខ្ពស់ចំពោះការបៀតបៀនផ្លូវភេទនៅក្រៅប្រព័ន្ធអនឡាញ និងនៅតាមប្រព័ន្ធអនឡាញ ដោយហេតុថាមនុស្សមិនសូវបង្ហាញខ្លួនច្រើននៅទីសាធារណៈ ហើយប្រព័ន្ធផ្សព្វផ្សាយសង្គមពឹងផ្អែកតែទៅលើវេទិកាចម្បងនៃអន្តរទំនាក់ទំនងបែបសង្គម។
- ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ ជាពិសេសចំពោះអ្នកនៅក្នុងស្ថានភាពសេដ្ឋកិច្ចមិនទៀងទាត់ ឬនៅពេលកំពុងចូលទៅរកសេវាឆ្លើយតបចំពោះការរាតត្បាតជំងឺជាសកល។
- ការបិទសាលារៀន ធ្វើឱ្យក្មេងស្រី និងស្ត្រីវ័យក្មេងត្រូវប្រឈមហានីភ័យកាន់តែខ្ពស់ចំពោះអំពើហិង្សាផ្លូវភេទ[2] ពីសំណាក់អ្នកជិតខាង និងសាច់ញាតិរបស់ខ្លួនក៏ដូចជាការមានផ្ទៃពោះដោយមិនចង់បាន។

---

[1] Fraser, E, *Impact of COVID-19 Pandemic on Violence against Women and Girls*, UKAID, March 2020.

[2] https://www.dw.com/en/coronavirus-fears-of-domestic-violence-child-abuse-rise/a-52847759
https://www.reuters.com/article/health-coronavirus-education-westafrica/teen-pregnancy-risk-rises-as-schools-shut-for-coronavirus-in-africa-idUSL8N2BC4GV

*ដោយហេតុនេះ យើងខ្ញុំសូមអំពាវនាវ ដល់រាជរដ្ឋាភិបាល អ្នកនយោបាយ អ្នកពាក់ព័ន្ធ និងពលរដ្ឋ ទាំងជាលក្ខណៈបុគ្គល និងជាលក្ខណៈសមូហភាព សូមឱ្យមានសកម្មភាពជាបន្ទាន់ដូចខាងក្រោម៖*

១) រដ្ឋាភិបាលគួរផ្តល់ព័ត៌មានដល់ស្ត្រី និងក្មេងស្រីក្រុមផ្សេងៗជាច្រើន[3] ឱ្យបានគ្រប់គ្រាន់ អំពីរបៀបបង្ការ នឹងឆ្លើយតបចំពោះជំងឺរាតត្បាត ដោយហេតុថាស្ត្រីដើរតួនាទីដ៏សំខាន់ នៅក្នុងការធ្វើជាអ្នកផ្តល់ព័ត៌មាននៅក្នុងសហគមន៍របស់ខ្លួន។ ព័ត៌មានគួរដាក់ឱ្យមានក្នុងទ្រង់ទ្រាយផ្សេងៗជាច្រើន រួមទាំងជារូបភាពផងដែរ ដើម្បីធានាឱ្យបានថា ស្ត្រី និងក្មេងស្រីដែលមានកម្រិតអប់រំ និងជាតិពន្ធុផ្សេងៗគ្នា អាចយល់អំពីស្ថានភាពនាពេលបច្ចុប្បន្នរបស់វីរុសនេះ។ ព័ត៌មានគួរលើកកម្ពស់ **ការរក្សាចម្ងាយខ្លួន** ជំនួសឱ្យការរក្សាគម្លាតសង្គម ដោយហេតុថា អារម្មណ៍តានតឹងបង្កឡើងដោយភាពឯកោផ្នែកសង្គម អាចបង្កើនហានីភ័យរបស់ស្ត្រី និងកុមារ ចំពោះអំពើហិង្សា និងផ្តល់ជម្រើសកាន់តែតិចសម្រាប់ពួកគេក្នុងការនិយាយ។

២) ទិន្នន័យទាក់ទងជាមួយការផ្ទុះជំងឺ និងការអនុវត្តកិច្ចឆ្លើយតបក្នុងគ្រាអាសន្ន ចាំបាច់ត្រូវញែកទៅតាមយេនឌ័រ អាយុ ជាតិពិន្ធុ និងពិការភាព រួចវិភាគយោងទៅតាមលក្ខណៈទាំងអស់នេះផងដែរ ដើម្បីផ្តល់ការយល់ដឹងសព្វជ្រុងជ្រោយអំពីភាពខុសគ្នាផ្នែកយេនឌ័រ នៅក្នុងការប៉ះពាល់ និងការព្យាបាល និងដើម្បីតាក់តែងវិធានការបម្រុងប្រយ័ត្ន និងវិធានការបង្ការជាក់លាក់។ ទោះយ៉ាងណាក្តី ទិន្នន័យដូចជា ឈ្មោះ រូបថត រោគវិនិច្ឆ័យបុគ្គល សាសនា ជាតិពិន្ធុ ពិការភាព អាសយដ្ឋាន និងព័ត៌មានឯកជនដទៃទៀតរបស់ជនដែលបានធ្វើតេស្តវិជ្ជមានមេរោគកូវីដ១៩ ឬសង្ស័យថាមានទំនាក់ទំនងជាមួយអ្នកផ្ទុកមេរោគ ពុំគួរដាក់ឱ្យមានជាសាធារណៈឡើយ ដើម្បីគោរពសិទ្ធិ ឯកជនភាព និងសេចក្តីថ្លៃថ្នូរជាមូលដ្ឋានរបស់ពួកគេ។

៣) ផែនការយុទ្ធសាស្ត្រប្រចាំប្រទេស ជាពិសេសផែនការយុទ្ធសាស្ត្រសម្រាប់ការត្រៀម និងឆ្លើយតបដែលត្រូវបានអភិវឌ្ឍដោយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM) ក្រសួងសុខាភិបាល ក្រសួងកិច្ចការនារី ចាំបាច់ត្រូវកែសម្រួលឡើងវិញ/សរសេរព្រាងដោយត្រូវដាក់បញ្ចូលធាតុចូលប្រកបដោយអត្ថន័យចំពោះស្ត្រី និងក្មេងស្រីនៅគ្រប់ដំណាក់កាលទាំងអស់ ហើយចាំបាច់ត្រូវផ្អែកលើការវិភាគយេនឌ័រដ៏រឹងមាំ ដោយត្រូវពិចារណាលើតួនាទីយេនឌ័រ ការទទួលខុសត្រូវ និងចរន្តទំនាក់ទំនង។ ចំណុចទាំងអស់នេះ គឺរួមមានទាំងការធានាឱ្យបានថា វិធានការរាំងខ្ទប់មេរោគ និងការកាត់បន្ថយហានីភ័យ ក៏ត្រូវឆ្លើយតបចំពោះបន្ទុកការងារថែទាំគ្មានប្រាក់ឈ្នួល និងហានីភ័យចំពោះ GBV ដែលកើនឡើងកាន់តែខ្ពស់ ជាពិសេសគឺចំពោះស្ត្រី និងក្មេងស្រីដែលរងផលប៉ះពាល់។

៤) ផ្តល់ជំនួយសេដ្ឋកិច្ចដល់ពលរដ្ឋលងាយប្រឈម ជាពិសេស ស្ត្រីប្រឈមនឹងហានីភ័យត្រូវបាត់បង់មុខរបរ ផ្អាករាល់ទម្រង់ទាំងអស់នៃការជម្លៀសចេញពីផ្ទះសម្បែង ដោយសារតែមិនមានសមត្ថភាពបង់ថ្លៃឈ្នួលផ្ទះ ឬសងប្រាក់កម្ចីដែលបានប្រើប្រាស់ដី/ផ្ទះ ជាវត្ថុបញ្ចាំ។ សេដ្ឋកិច្ចកម្ពុជា បានរងគ្រោះរួចទៅហើយអាស្រ័យដោយជំងឺ កូវីដ១៩ ដោយមានបន្ទុកការចំណាយផ្នែកសេដ្ឋកិច្ចខ្ពស់ដែលស្ត្រីត្រូវរ៉ាប់រងជាពិសេស ដោយហេតុថា ស្ត្រីគឺជាចំនួនភាគច្រើននៃអ្នកខ្ចីកម្ចីពីស្ថាប័នមីក្រូហិរញ្ញវត្ថុ ហើយពួកគាត់ប្រហែលជាត្រូវបាត់បង់ការងាររបស់ខ្លួន អាស្រ័យដោយការបិទអាជីវកម្មរបស់និយោជក និង/ឬតម្រូវការរបស់ស្ត្រី ក្នុងការដាក់ខ្លួនឯងឱ្យនៅដាច់ដោយឡែក ឬថែទាំអ្នកដទៃ។ ធនាគារជាតិកម្ពុជា និងធនាគារពាណិជ្ជកម្ម ព្រមទាំងស្ថាប័នមីក្រូហិរញ្ញវត្ថុដទៃទៀត គួរសហការយ៉ាងជិតស្និទ្ធដើម្បី ដោះស្រាយស្ថានភាពមិន

[3] ជាពិសេសស្ត្រី និងក្មេងស្រីជួបការលំបាក និងស្ត្រី និងក្មេងស្រីងាយរងគ្រោះដូចជាក្រុមជនជាតិដើមភាគតិច ស្ត្រីរស់នៅជាមួយជំងឺអេដស៍ /មេរោគអេដស៍ និងអ្នកមានស្ថានភាពវេជ្ជសាស្ត្រដទៃទៀត ស្ត្រីរស់នៅក្នុងតំបន់ជនបទ និងដាច់ស្រយាល អ្នកកំពុងធ្វើការក្នុងមុខរបរមិនទៀងទាត់ និងអ្នកជាអាណាព្យាបាលចម្បង

ធ្លាប់កើតមានពីមុនមកនាពេលនេះឱ្យបានសមស្រប និងដោយចិត្តមេត្តា ជាពិសេសចំពោះអ្នកខ្ចីខ្នាតតូច និង សហគ្រាសខ្នាតតូចនិងមធ្យម រួមទាំងការលុបចោលការផាកពិន័យសមតុល្យអប្បបរមា និងការថ្លៃសេវាធនាគារ។ គួរផ្តល់លំនៅដ្ឋានសុវត្ថិភាព ព្រមទាំងលទ្ធភាពដើម្បីទទួលបានទឹកស្អាត និងអនាម័យជូនជនគ្រប់រូបទាំងអស់ដែលបច្ចុប្បន្នពុំមានលំនៅដ្ឋានសមស្រប ដើម្បីអាចឱ្យពួកគាត់ការពារខ្លួនពីការរាតត្បាតជំងឺជាសកល និងដើម្បីធ្វើឱ្យការសាយភាយមេរោគមានការថយចុះ។

**៥)** លំនៅដ្ឋានសុវត្ថិភាព ព្រមជាមួយលទ្ធភាពសមស្របដើម្បីទទួលបានទឹកស្អាត និងអនាម័យ គួរត្រូវបានផ្តល់ទៅឱ្យជនអនាថា និងជនមិនមានលំនៅដ្ឋានគ្រប់គ្រាន់ ដើម្បីការពារពួកគេពីការរាតត្បាតជំងឺជាសកល បង្ការការសាយភាយរបស់មេរោគ និងកាត់បន្ថយហានីភ័យរបស់ពួកគេចំពោះ GBV។

**៦)** ដាក់ឱ្យមានមធ្យោបាយឌីជីថល ប្រកបដោយនវានុវត្តន៍ ដែលមានការបន្ថែមការផ្តោតទៅលើតួនាទីបុរស និងជម្រុញឲ្យបុរសចែករំលែកការងារផ្ទះ ដើម្បីឲ្យសិស្សានុសិស្សមានលទ្ធភាពអាចទទួលបានការអប់រំ បើទោះបីជាសាលារៀនត្រូវបិទទ្វារក្តី។ ចំណុចនេះមានភាពចាំបាច់ណាស់ដើម្បីកាត់បន្ថយ បន្ទុកកាន់តែធ្ងន់ធ្ងរ នៃការងារថែទាំគ្មានប្រាក់កម្រៃ ដែលស្ត្រីចាំបាច់ត្រូវធ្វើនាពេលនេះ ពេលដែលកូនៗរបស់ខ្លួនមិនទៅសាលារៀន។ រដ្ឋាភិបាលចាំបាច់ត្រូវធានាឱ្យបានថា សិស្សានុសិស្សនៅតំបន់ជនបទ ក៏មានលទ្ធភាពអាចទទួលបានមធ្យោបាយឌីជីថល ដើម្បីសិក្សាតាមកម្មវិធីសិក្សាដែលបានគ្រោងទុក ដូចគ្នាជាមួយសិស្សានុសិស្សនៅតំបន់ទីប្រជុំជន និងអ្នកដទៃទៀតដែលមានលទ្ធភាពប្រសើរក្នុងការទទួលបានបច្ចេកវិទ្យាផងដែរ។

**៧)** រដ្ឋាភិបាលគួរធានាថា សេវាសុខាភិបាលទាំងអស់នៅតែមានជូនចំពោះគ្រប់ស្ត្រី និងក្មេងស្រីទាំងអស់ ព្រមទាំងប្រជាជនមាននិន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញចេញផ្នែកយេនឌ័រផ្សេងៗគ្នា ក្នុងអំឡុងពេលមានវិបត្តិនេះ ដោយត្រូវយកចិត្តទុកដាក់ជាពិសេសចំពោះមនុស្សចាស់ ជនពិការ ស្ត្រីមានផ្ទៃពោះ ស្ត្រីទើបសម្រាលកូន និងអ្នកមានបញ្ហាសុខភាពផ្នែកវេជ្ជសាស្ត្រ រួមទាំងការរំលូតកូនដោយសុវត្ថិភាពសម្រាប់ការមានផ្ទៃពោះដែលគេមិនចង់បាន និងការថែទាំសុខភាពសម្រាប់អ្នករស់រានពីអំពើហិង្សាផ្លូវភេទ (កញ្ចប់ PEP ការធ្វើតេស្តពិនិត្យផ្ទៃពោះ...)។ ចាំបាច់ត្រូវផ្តល់ការសួរសុខទុក្ខតាមផ្ទះ និងបណ្តាញជំនួយពិសេស ព្រមទាំងវេទិកាឌីជីថល ដែលត្រូវដាក់ឱ្យមានដើម្បីផ្តល់សេវាសុខភាពដែលចាំបាច់សម្រាប់ក្រុមទាំងអស់នេះផងដែរ។ សេចក្តីត្រូវការទាំងនេះមានដូចជា ការសំរាលកូន អំពើហិង្សាក្នុងគ្រួសារ ការធ្វើបាបផ្លូវភេទ ការរំលោភបំពានលើកុមារ និងសេវាសុខភាពផ្លូវចិត្ត។ បន្ថែមលើនេះ មនុស្សវ័យជំទង់ដែលមានផ្ទៃពោះក្នុងអំឡុងពេលការរាតត្បាតជំងឺជាសកល គួរបានទទួលការគាំទ្រ និងការធានាសិទ្ធិដើម្បីបន្តការអប់រំរបស់ខ្លួន។

**៨)** ត្រូវមានកិច្ចខិតខំបន្ថែមទៀត ដើម្បីលើកកម្ពស់ការយល់ដឹងអំពីអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សាផ្លូវភេទ សុខភាពផ្លូវភេទ តាមរយៈការប្រើប្រាស់បណ្តាញប្រព័ន្ធផ្សព្វផ្សាយនានា ដើម្បីរារាំងការរំលោភបំពាន និងបង្ការការមានផ្ទៃពោះដែលគេមិនចង់បាន និងការមានផ្ទៃពោះរបស់មនុស្សវ័យជំទង់ អាស្រ័យដោយការរាតត្បាតជំងឺ។ បន្ថែមលើការបន្តផែនការ ក្នុងការផ្តល់សេវាប្រកបដោយការគាំទ្រសំរាប់ជនរងគ្រោះ GBV នៅក្នុងមន្ទីរពេទ្យ គ្រឹះស្ថានថែទាំសុខភាពបឋម និងមធ្យម គួរទទួលខុសត្រូវចម្បងចំពោះអ្នករស់រានពី GBV និងផ្តល់អាទិភាពដើម្បីទទួលបានសេវាសុខភាពផ្លូវភេទ និងសេវាសុខភាពបន្តពូជ ហើយបញ្ជូនករណីទៅកាន់មន្ទីរពេទ្យកម្រិតឧត្តម តែនៅពេលដែលចាំបាច់ត្រូវការការថែទាំកម្រិតខ្ពស់ជាងនេះប៉ុណ្ណោះ។ រដ្ឋាភិបាលចាំបាច់ត្រូវបំពាក់ដល់បុគ្គលិកសុខាភិបាលដែលទទួលខុសត្រូវ ឆ្លើយតបចំពោះមេរោគកូវីដ១៩ នូវជំនាញកម្រិតមូលដ្ឋាន ក្នុងការឆ្លើយតបចំពោះការបើកបង្ហាញ អំពីករណី GBV ដែលអាចពាក់ព័ន្ធជាមួយការរាតត្បាតជំងឺជាសកល ឬត្រូវបានធ្វើឱ្យកាន់តែអាក្រក់ឡើងដោយការរាតត្បាតនេះ នៅក្នុងលក្ខណៈប្រកបដោយក្តីមេត្តា

គ្មានការវិនិច្ឆ័យ និងយកចិត្តទុកដាក់ផ្នែកយេនឌ័រ។ បុគ្គលិកទាំងនេះក៏គួរតែយល់ច្បាស់ អំពីនីតិវិធីក្នុងការបញ្ជូន និងទីកន្លែងគោលដៅសម្រាប់ការថែទាំ និង/ឬការព្យាបាលបន្ថែមទៀត ក្នុងលក្ខណៈយ៉ាងទាន់ពេលវេលា។ ចាំបាច់ត្រូវដាក់បញ្ចូលការគាំទ្រចំពោះសេចក្តីត្រូវការផ្នែកចិត្តសង្គមនៅគ្រប់កម្រិតទាំងអស់។

៩) គ្រឹះស្ថានព្យាបាល និងបុគ្គលិកសុខាភិបាលឆ្លើយតបនឹងមេរោគ កូវីដ១៩គួរមានការយកចិត្តទុកដាក់ខ្ពស់ចំពោះផ្នែក យេនឌ័រដើម្បីធានាសន្តិសុខរបស់ស្ត្រី និងក្មេងស្រីនិងធានាកិច្ចការពារពីការបៀតបៀននិងGBV ទម្រង់ដទៃទៀត។

១០) ក្រសួងមហាផ្ទៃគួរចេញ "ទម្រង់ការឆ្លើយតបចំពោះមេរោគកូវីដ១៩" សម្រាប់គ្រប់ពន្ធនាគារទាំងអស់ នៅទូទាំងប្រទេស ដើម្បីបង្ការកុំឱ្យមានការផ្ទុះមេរោគកូវីដ១៩ ក្នុងពន្ធនាគារ។ សុវត្ថិភាព និងសុខុមាលភាពផ្នែករាងកាយសំរាប់ស្ត្រី និងកុមារជាប់ពន្ធនាគារ គួរតែជាអាទិភាព ហើយសិទ្ធិរបស់ពួកគេក្នុងការទទួលបានការថែទាំសុខភាព ប្រកបដោយគុណភាព ចាំបាច់ត្រូវបានគោរពក្នុងអំឡុងពេលការរាតត្បាតជំងឺជាសកលនេះ។ ដោយហេតុនេះ ជាការចាំបាច់ដែលត្រូវចាត់វិធានការជាបន្ទាន់ ដើម្បីជំរុញឱ្យអ្នកដែលប្រព្រឹត្តបទល្មើសមិនពាក់ព័ន្ធនឹងអំពើហិង្សា មុនពេលសវនាការអាចត្រឡប់ទៅផ្ទះ ដោយអាចស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការជំនួសវិញ និងត្រូវពន្លឿនរយៈពេលបំពេញទោសសម្រាប់អ្នកដែលបាន ទទួលទោស ២/៣ នៃរយៈពេលជាប់ពន្ធនាគាររបស់ខ្លួន ជាពិសេសគឺសម្រាប់ស្ត្រីរងគ្រោះ ដូចជាស្ត្រីមានផ្ទៃពោះ ស្ត្រីដែលមានកូននៅជាមួយ និងស្ត្រីមានស្ថានភាពវេជ្ជសាស្ត្រជាប់ខ្លួន ដើម្បីឱ្យចេញពីពន្ធនាគារដែលមានលក្ខណៈចង្អៀតរបស់កម្ពុជានៅក្នុងអំឡុងពេលនៃការរីករាលដាលជំងឺជាសកលនេះ។

ពន្ធនាគារទាំងអស់ គួរបំពាក់នូវសម្ភារចាំបាច់ក្នុងការតាមដានសីតុណ្ហភាព សាប៊ូ សំឡីអនាម័យ ខោទឹកនោមអនាម័យ សារធាតុសម្លាប់មេរោគ និងមុខទំនិញប្រហាក់ប្រហែលដទៃទៀត ដើម្បីកំចាត់មេរោគ និងធានាដល់សុវត្ថិភាពទាំងអស់គ្នា។ ការប្រាស្រ័យទាក់ទងសួរសុខទុក្ខរបស់សាច់ញាតិរបស់ពួកគេតាមតែអាចធ្វើបានដូចជាការសន្ទនាតាមវីដេអូនិង/ឬការសន្ទនាតាមទូរស័ព្ទជាដើម ដែលនិតិវិធីនៃការសួរសុខទុក្ខនេះត្រូវដាក់ចេញឲ្យបានឆាប់។

*យើងរួមសាមគ្គីគ្នាជាមួយរដ្ឋាភិបាល អ្នកពាក់ព័ន្ធ និងពលរដ្ឋទាំងអស់ ដើម្បីប្រយុទ្ធប្រឆាំងជាមួយជំងឺកូវីដ១៩ ក្នុងប្រទេសកម្ពុជា។*

សម្រាប់ព័ត៌មានបន្ថែម ឬការបកស្រាយបញ្ជាក់សូមទំនាក់ទំនងមកកាន់អ្នកតំណាងរបស់បណ្តាញដូចខាងក្រោម៖

- អ្នកស្រី រស់ សុភាព នាយិកាប្រតិបត្តិនៃអង្គការយេនឌ័រ និងអភិវឌ្ឍដើម្បីកម្ពុជា (GADC)
  លេខទូរស័ព្ទ៖ ០១២ ៦២៧ ៨៥៧
- អ្នកស្រី ចក់ សុភាព នាយិកាប្រតិបត្តិនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)
  លេខទូរស័ព្ទ៖ ០១១ ៩៤៣ ២១៣
- កញ្ញា បុណ្យ រចនា នាយិកាប្រតិបត្តិនៃអង្គការក្លាហាន (Klahaan)
  លេខទូរស័ព្ទ ៖ ០៨៩ ៤៧៦ ១៤៦
- លោក សុខ លាំង អ្នកជំនាញឯករាជ្យផ្នែកយេនឌ័រនិងសង្គមវិទ្យា និងជាគណកម្មាធិការបណ្តាញយេនឌ័រ និងអភិវឌ្ឍ (GADNet) ទូរស័ព្ទ៖ ០១២ ៥៨៨ ០៨១

អង្គការ ស្ថាប័ន និងសមាជិក ដែលគាំទ្រទៅលើឯកសារគោលជំហររួមរបស់អង្គការសង្គមស៊ីវិលកម្ពុជា

នេះមានដូចខាងក្រោមៈ

១. អង្គការយេនឌ័រ និងអភិវឌ្ឍដើម្បីកម្ពុជា (GADC)

២. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)

៣. អង្គការក្លាហាន (Klahaan)

៤. អង្គការនារីដើម្បីសន្តិភាព

៥. អង្គការរចនាស្ត្រី

៦. អង្គការខុមប្រែវល

៧. អង្គការអមរា (AMARA)

៨. អង្គការADD International Cambodia

៩. អង្គការក្រុមការងារដើម្បីដោះស្រាយទំនាស់ (កដទ) (ACT)

១០. អង្គការបន្ទាយស្រី (Banteay Srei)

១១. ក្រុមសន្សំប្រាក់នារី (LSG)

១២. អង្គការភ្នំស្រីដើម្បីការអភិវឌ្ឍន៍ (PSOD)

១៣. អង្គការ Planete Enfants and Developpement (PE&D)

១៤. អង្គការទស្សនៈពិភពលោកអន្តរជាតិប្រចាំកម្ពុជា (World Vision)

១៥. លោក សុខ លាំង, អ្នកជំនាញឯកវាជ្ជផ្នែកយេនឌ័រនិងសង្គមវិទ្យានិងជាគណកម្មាធិការបណ្តាញយេនឌ័រ និងអភិវឌ្ឍ (GADNet)